## ជំរំមាតិកាប្រសព្វ

# បើកតង់ទទួលពាក្យ!

PROSOB CONTENT CAMP

Training camp for content creators



អានជាភាសាអង់គ្លេស

### អំពីកម្មវិធី៖

កម្មវិធីជំរំមាតិកាសង្គមប្រសព្វមានរយៈពេល៤ខែសម្រាប់ជួយគាំទ្រ ដល់ អ្នក ដែលជាអ្នកបង្កើតមាតិកាផ្សព្វផ្សាយថ្មីៗ ក្នុងការទទួលបាននូវ បទពិសោធន៍ បណ្តាញក្នុងវិស័យ ការគាំទ្រ ការសហការបែបច្នៃប្រឌិត ដើម្បីបង្កើតមាតិកាពី រឿងរ៉ាវឬជាខ្លឹមសារទាក់ទងនិងការចូលរួមរបស់យុវជនយើងក្នុងកិច្ចការងារ សង្គម បរិស្ថាន និងសាធារណៈផ្សេងៗក្នុងសហគមន៍យើង។

ចូលរួមនាំយកភាពច្នៃប្រឌិតរបស់អ្នក មកជំរំជាមាតិកាដើម្បីផ្តល់ជាចំណេះដឹង បំផុសគំនិតថ្មីៗ និងបង្កើតឲ្យមានទំនាក់ទំនងដ៏មានអត្ថន័យដល់អ្នកតាមដានរបស់អ្នក។

បង្កើតមាតិកាសង្គមយ៉ាងម៉េចដើម្បីទាក់ចិត្តអ្នកតាមដាន ឲ្យមកទងនឹងសារដ៏មានអត្ថន័យរបស់យើង?

### ជំរំសម្រាប់អ្នកចាប់ផ្តើមបង្កើតមាតិកា៖

អ្នកដែលត្រៀមខ្លួនរួចជាស្រេចក្នុងការចូលរួមបេសកម្មជាបន្តបន្ទាប់របស់ជំរំមាតិកាប្រសព្វ ក្នុងការចូលរួមចងក្រងសារដ៏មានអត្ថន័យបន្ថែមទៀតសម្រាប់អ្នកតាមដានរបស់យើង។

លក្ខខណ្ឌ៖

មានចំណេះដឹង និងជំនាញខ្លះៗក្នុងការបង្កើតមាតិកា (ជាសំណេរ ជារូបភាពឌីហ្សាញ វិឌីអូ សំលេង)

ចាប់ផ្តើមបង្កើតជាវេទិកាចែកចាយមាតិកា(ជាFacebook ផេក TikTok ។ល។)

មានចិត្ត និងឆន្ទះក្នុងការបង្កើតមាតិកាទាក់ទងនឹងការចូលរួមរបស់យុវជនក្នុងសង្គម បរិស្ថាន និងកិច្ចការស៊ីវិលរបស់សហគមន៍យើង

មានចិត្ត និងឆន្ទះក្នុងការងារសហការណ៍បែបច្នៃប្រឌិតជាមួយអ្នកដទៃ

ត្រៀមខ្លួនរួចជាស្រេចក្នុងការចាប់ផ្តើមបេសកម្មរបស់ជំរំរបស់យើង

ត្រៀមៗ!

### អត្ថប្រយោជន៍៖

<u>ការរៀន & លេង 📖🎮</u>

កម្មវិធីយើងនឹងផ្សារអ្នកឲ្យភ្ជាប់ជាមួយនឹងការរៀន និងការអនុវត្តបែបសហការណ៍ (collab) មិនថាជាមួយអ្នកចូលរួមដទៃទៀត អ្នកបង្វឹកណែនាំ ឬអ្នកតាមដានទេ ព្រោះវានឹងជួយបំផុសឲ្យមានទំនាក់ទំនង និងបទពិសោធន៍ដ៏មានអត្ថន័យ ហើយភាពសប្បាយរីករាយជុំគ្នា។

<u>បេសកកម្មច្នៃប្រឌិត និងបង្កើតមាតិកា🎨</u>

យើងមានបេសកកម្មពាតង់ សម្រាប់អ្នក ក្នុងការបង្កើតមាតិកាចំនួន៣០ទាក់ទងនិងការចូលរួមរបស់យុវជន យើងក្នុងកិច្ចការងារ សង្គម បរិស្ថាន និងសាធារណៈ។

ការបង្កើតមាតិកា តាមទម្រង់ផ្សេងៗ

ការចងក្រងមាតិកាជាផលិតផលមួយ និង

ការផ្សព្វផ្សាយផលិតផលនោះទៅកាន់បណ្តាញផ្សេងៗ

<u>ការគាំទ្ររុំជុំវិញបេសកកម្មយើង🙌 🙌</u>

ក្នុងការផលិតមាតិកាទាំង៣០ ក្នុងតង់ទាំងបីនៃកម្មវិធីយើង អ្នកនឹងទទួលបាន៖

ការគាំទ្រជាកញ្ចប់ថវិកាគាំទ្រគម្រោង សរុបចំនួន ១១៨៩ដុល្លា (Gross)

ការគាំទ្រពីអ្នកបង្វឹកណែនាំដែលជាអ្នកជំនាញក្នុងវិស័យបង្កើតមាតិកា ទំនាក់ទំនង និង ប្រព័ន្ធផ្សព្វផ្សាយ

ដើម្បីឲ្យសារក្នុងមាតិការបស់អ្នកផ្សាយដល់អ្នកតាមដានកាន់តែច្រើន យើងនឹងចេញផ្សាយ (Distribution/featuring)មាតិការបស់អ្នកនៅលើទំព័រProsob-ប្រសព្វផងដែរ

<u>ចូលរួមជាសមាជិកក្នុងក្លិប💯</u>

ឱកាសក្នុងការរួមសកម្មភាព ឬកម្មវិធីផ្សេងៗទៀត

ជាសមាជិកដែលនិងបន្តមានការគាំទ្រពីប្រសព្វ-Prosob community និងការសហការណ៍(collab)ក្នុងគម្រោងផ្សេងទៀត

ក្លិបយើងគាំទ្រគ្នាបង្កើតសារដ៏មានខ្លឹមសារ និងធ្វើម៉េចឈរជើងឲ្យបាន

## ជំរំមាតិកាប្រសព្វ

# បើកតង់ទទួលពាក្យ!

PROSOB CONTENT CAMP

Training camp for content creators

## ការដាក់ពាក្យ

តោះវេចភាពច្នៃប្រឌិត កក់ពេលវេលា ដាក់ពាក្យជំរំធ្វើមាតិកាសង្គមជាមួយគ្នា! បំពេញពាក្យនៅទីនេះ៖

ចុចទីនេះ

បិទពាក្យនៅថ្ងៃទី២៦ កញ្ញា ២០២៣

បញ្ជាក់៖ យើងមកជុំរុំគ្នាធ្វើបេសកកម្មតាមតង់ មិនមែនទៅបោះជំរំបោះតង់ទេណា!

### បន្ថែមអំពីមាតិកាសង្គម៖

ប្រធានបទ៖ ប្រើភាពច្នៃប្រឌិតរបស់អ្នកបង្កើតមាតិកាដ៏មានខ្លឹមសារ ទាក់ទងនិងបង្កើតឲ្យមានការជជែក បំផុសគំនិត ផ្តល់ជាព័ត៌មានឬចំណេះដឹងទាក់ទងនិងការចូលរួមរបស់យើងក្នុងកិច្ចការងារ សង្គម បរិស្ថាន និង សាធារណៈ៖

- យេនឌ័រ
- បរិស្ថាន និងចីរភាព
- ធុរកិច្ច & អាជីវកម្ម
- ការអប់រំ
- ចំនីអាហារ & កសិកម្ម
- សុខភាព & សុខមាលភាព
- ការងារសហគមន៍
- ភាពចម្រុះ និង បរិយាប័ន្នសង្គម

ទម្រង់មាតិកា

- សំលេង
- វីឌូអូ
- រូបថត គំនូរ & រូបភាពក្រាហ្វិក
- សំណេរ

បើអ្នកមានជាសំនួរផ្សេងៗ សូមទាក់ទងមក វណ្ណា មកចាំគាត់ជួយឆ្លើយ៖

អ៊ីម៉ែល៖ vandara.sin@impacthub.net

### ដំណើររបស់ជំរំយើង

១២-២៦កញ្ញា បើកតង់ទទួលពាក្យ ស្វែងរកអ្នកក្លាហានចាប់ផ្តើមបង្កើតមាតិកាសង្គម (young content creators and media practitioners)
បិទពាក្យ ៦កញ្ញា ២០២៣

១២ តុលា ២០២៣៖ 🏕️អនឡាញខលត្រៀមចិត្ត ត្រៀមកាយ  (ល្ងាច)

២១ តុលា ២០២៣៖ 🏕️🏝️ថ្ងៃជំរំភាពច្នៃប្រឌិត-រៀនពីការបង្កើតមាតិកាសង្គម(ចូលរួមដោយផ្ទាល់-មួយថ្ងៃពេញ)

🏃បេសកកម្មបង្កើតមាតិកា៖ តង់ទី១
២៨ តុលា ២០២៣៖ 🏕️🏃ថ្ងៃជំរំបង្កើតមាតិកាតង់ទី១ (ចូលរួមដោយផ្ទាល់-មួយថ្ងៃពេញ)
តុលា-វិច្ឆិកា ២០២៣៖ 🏕️✏️ការបង្កើតមាតិកាក្នុងតង់ទី១ (អ្នកមានរយៈពេល៣សប្តាហ៍)

🏃បេសកកម្មបង្កើតមាតិកា៖ តង់ទី២
២៥ វិច្ឆិកា ២០២៣៖ 🏕️🏃ថ្ងៃជំរំបង្កើតមាតិកាតង់ទី២(ចូលរួមដោយផ្ទាល់-មួយថ្ងៃពេញ)
វិច្ឆិកា-ធ្នូ ២០២៣៖ 🏕️✏️ការបង្កើតមាតិកាក្នុងតង់ទី២ (អ្នកមានរយៈពេល៣សប្តាហ៍)

🏃បេសកកម្មបង្កើតមាតិកា៖ តង់ទី៣
១៣ មករា ២០២៤៖ 🏕️🏃ថ្ងៃជំរំបង្កើតមាតិកាតង់ទី៣(ចូលរួមដោយផ្ទាល់-មួយថ្ងៃពេញ)
មករា-កុម្ភៈ ២០២៤៖ 🏕️✏️ការបង្កើតមាតិកាក្នុងតង់ទី៣ (អ្នកមានរយៈពេល៣សប្តាហ៍)

៣០ មិនា ២០២៤៖ ថ្ងៃជំរំប្រមូលផល(និងរឿងរ៉ាវល្អៗពីការងារយើងខំធ្វើ)(ចូលរួមដោយផ្ទាល់-មួយថ្ងៃពេញ)

បញ្ជាក់៖ រាល់ការចូលរួមដោយផ្ទាល់(មួយថ្ងៃពេញ) យើងនឹងធ្វើឡើងនៅក្រុងភ្នំពេញ ដែលអាហារថ្ងៃត្រង់ និងសម្រន់របស់អ្នកនឹងត្រូវបានរ៉ាប់រងពីអ្នករៀបចំ